# ក្រសួងការងារសហរដ្ឋអាមេរិក

# របកគំហើញឆ្នាំ 2023 ស្តីពីទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ

## កម្ពុជា

នៅឆ្នាំ 2023 ប្រទេសកម្ពុជាមានការជឿនលឿនតិចតួច ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីលុបបំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ។ រដ្ឋាភិបាលបានសង្គ្រោះកុមារចំនួន ១២៣ នាក់ ចេញពីកន្លែងអាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទ និងការជួញដូរមនុស្ស និងបានដាក់ចេញគោលការណ៍ណែនាំស្តីពីសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ នៅចំពោះមុខនៃករណីកើនឡើងនៃការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ។ ទោះជាយ៉ាងនេះក្តី បើទោះបីជាមានគំនិតផ្តួចផ្តើមថ្មីទាំងនេះ ដើម្បីដោះស្រាយពលកម្មកុមារក៏ដោយ ក៏ប្រទេសកម្ពុជាត្រូវបានគេវាយតម្លៃថា មានការរីកចម្រើនតិចតួចប៉ុណ្ណោះ ដោយសារតែរដ្ឋាភិបាលបានខកខានក្នុងការចាត់វិធានការសកម្ម ដើម្បីស៊ើបអង្កេត ចោទប្រកាន់ ផ្តន្ទាទោស និងកាត់ទោសឲ្យជាប់ពន្ធនាគារចំពោះមន្ត្រីសាធារណៈទាំងឡាយណា ដែលចូលរួម ឬជួយសម្រួលដល់ទម្រង់អាក្រក់បំផុត នៃពលកម្មកុមារ រួមទាំងការកេងប្រវ័ញ្ចអាជីវកម្មផ្លូវភេទលើកុមារ និងពលកម្ម ដោយបង្ខំនៅសិប្បកម្មឡឥដ្ឋ ដើម្បីដោះបំណុល។ លើសពីនេះទៅទៀត ចៅក្រម ប៉ូលិស និងមន្ត្រីអធិការកិច្ចការងារ ត្រូវបាន រាយការណ៍ថាបានទទួលសំណូកសូកប៉ាន់ ដើម្បីមើលរំលងបទល្មើសលើពលកម្មកុមារ នៅក្នុងប្រទេស ជាពិសេស នៅពេលដែលចារិងការចោទប្រកាន់ថាមាន ទំនាក់ទនងជាមួយរដ្ឋាភិបាល។ ជាចុងក្រោយ ច្បាប់ហាមឃាត់អាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៅតែមិនគ្រប់គ្រាន់ ដោយសារតែការប្រើប្រាស់ ឬការយកកុមារមកឲ្យសម្តែងរូបភាពអាសអាភាស មិនត្រូវ បានហាមឃាត់ដោយច្បាប់ព្រហ្មទណ្ឌ។

ចំណាត់ការដែលស្នើឲ្យរដ្ឋាភិបាលធ្វើ ដូចខាងក្រោមនេះ នឹងជួយភ្ជិតគម្លាត USDOL ដូចដែលបានកំណត់ឃើញនៅក្នុងការការអនុវត្តរបស់ប្រទេសកម្ពុជា ពាក់ព័ន្ធនឹងការប្តេជ្ញាជាអន្តរជាតិ ដើម្បីលុបបំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ។

| ផ្នែក | សកម្មភាពដែលស្នើឲ្យធ្វើ |
|---|---|
| ក្របខ័ណ្ឌច្បាប់ | ធានាឲ្យមានអាយុអប្បបរមាសម្រាប់ការងារ ដោយត្រូវអនុវត្តលើគ្រប់កុមារទាំងអស់ រួមទាំងកុមារដែលធ្វើការក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ និង ពលករកុមារតាមផ្ទះ ដែលបងប្អូនរបស់ពួកគាត់ជួលឲ្យធ្វើការ។ |
| | ធានាឲ្យមានច្បាប់ព្រហ្មទណ្ឌ ដែលហាមឃាត់ព្រហ្មទណ្ឌលើការប្រើប្រាស់កុមារសម្រាប់សម្តែងរូបអាសអាភាស មិនមែនតែនៅតាមទីសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែត្រូវហាមឃាត់នៅតាមទីកន្លែងឯកជនផងដែរ ឬតាមរយៈការប្រើប្រាស់សារទំនាក់ទំនង និងបច្ចេកវិទ្យាព័ត៌មានវិទ្យា។ |
| | ធានាឲ្យមានច្បាប់ព្រហ្មទណ្ឌហាមឃាត់ការរាល់ការជ្រើសរើសកុមារអាយុក្រោម ១៨ ឆ្នាំ ដោយក្រុមប្រដាប់អាវុធមិនមែនរដ្ឋ។ |

| ផ្នែក | សកម្មភាពដែលស្នើឲ្យធ្វើ |
|---|---|
| | ធានាផ្តល់ការអប់រំដោយឥតគិតថ្លៃ ទៅដល់កុមារទាំងអស់ មិនថាកុមារទាំងនោះជាពលរដ្ឋ ឬមិនមែនជាពលរដ្ឋនោះឡើយ។ |
| | បង្កើតច្បាប់កំណត់អាយុ ដែលត្រូវទទួលបានការអប់រំជាកំហិតរហូតដល់អាយុ ១៥ ឆ្នាំ ឲ្យស្របគ្នាទៅនឹងការកំណត់អាយុអប្បបរមាសម្រាប់ការងារដែរ។ |
| ការពង្រឹង | កសាងសមត្ថភាពរបស់អាជ្ញាធរពង្រឹងការអនុវត្តច្បាប់ការងារ ដើម្បីពង្រឹងការអនុវត្តច្បាប់ពលកម្មកុមារ និងបទប្បញ្ញត្តិអំពីពលកម្មដោយបង្ខំ ដោយផ្តល់ឱកាសបណ្តុះបណ្តាលផ្នែកបច្ចេកទេសបន្ថែមទៀត អំពីរបៀបកំណត់ពលកម្មកុមារឲ្យបានត្រឹមត្រូវ ក្នុងអំឡុងពេលចុះធ្វើអធិការកិច្ច។ |
| | ធានាឲ្យមានអ្នកចុះធ្វើអធិការកិច្ចនៅការដ្ឋានសំណង់ មានការបណ្តុះបណ្តាលស្តីការបំពានពលកម្មកុមារ និងវគ្គបណ្តុះបណ្តាលនោះ ត្រូវមានការសម្របសម្រួលគ្នាជាមួយអធិការដ្ឋាននៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈអធិការកិច្ច ដើម្បីធានាសុវត្ថិភាពរបស់អធិការ។ |
| | បង្កើនចំនួនមន្ត្រីអធិការកិច្ចការងារ ឲ្យឡើងដល់ ៦២៨ នាក់ ដើម្បីធានាត្រួតពិនិត្យឲ្យបានគ្រប់គ្រាន់ទៅលើកម្លាំងពលកម្មនៅកម្ពុជា ដែលមានចំនួន ៩,៤១៨,៦០០ នាក់ ដែលរួមមានទាំងវិស័យក្រៅប្រព័ន្ធផងដែរ។ |
| | ធានាឲ្យមាន និងអនុញ្ញាតឲ្យមន្ត្រីអធិការកិច្ចការងារ ចុះធ្វើអធិការកិច្ចដោយមិនប្រកាសឲ្យដឹងមុន នៅគ្រប់វិស័យ ដែលមានសេចក្តីរាយការណ៍ថាមានពលកម្មកុមារ រួមទាំងនៅក្នុងវិស័យក្រៅប្រព័ន្ធ សំណង់ និងកម្សាន្ត និងដាក់ពិន័យ នៅពេល ដែលរកឃើញថាមានការបំពានពលកម្មកុមារ។ |
| | ប្រមូល រក្សាទុកឱ្យបានត្រឹមត្រូវ និងបញ្ចេញជាសាធារណៈ នូវទិន្នន័យដែលបានបែងចែកលម្អិត ស្តីអំពីកិច្ចខិតខំប្រឹងប្រែងពង្រឹងការអនុវត្តច្បាប់ការងារ និងច្បាប់ព្រហ្មទណ្ឌ រួមទាំងចំនួននៃមូលនិធិអធិការដ្ឋានការងារ ការបណ្តុះបណ្តាលបឋម សម្រាប់អ្នកស៊ើបអង្កេតថ្មីក្នុងករណីព្រហ្មទណ្ឌ ការបំពេញការធ្វើអធិការកិច្ចជាប្រចាំ ចំនួនករណីដែលត្រូវបានផ្តើមចោទប្រកាន់ ចំនួនករណីដែលត្រូវបានផ្តន្ទាទោស ចំនួនករណីដែលបានដាក់ពិន័យ ចំពោះការរំលោភបំពានទាំងឡាយណា ពាក់ព័ន្ធនឹងទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ។ |
| | ធានាឲ្យបាន ថាមានចំណាត់ការលើការប្រព្រឹត្តិខុសរបស់មន្ត្រីសាធារណៈ នៅរាល់ទីភ្នាក់ងារពង្រឹងការអនុវត្តច្បាប់ រួមទាំងការមិនទទួលសំណូកសូកប៉ាន់ ដើម្បីជាថ្នូរនឹងការកែលទ្ធផលនៃសំណុំរឿង ឬការក្លែងបន្លំឯកសារអត្តសញ្ញាណ ដើម្បីគោលបំណងនៃការជួញដូរមនុស្ស ការលួចផ្តល់ព័ត៌មាននៅមុនការ ការឆ្មក់បង្ក្រាប និងការស៊ើបអង្កេត និងការចោទប្រកាន់បុគ្គលដែលជាប់ពាក់ព័ន្ធនឹងនយោបាយ និងមន្ត្រីរដ្ឋាភិបាល ដែលចូលដៃក្នុងការសម្របសម្រួល និងបានចំណេញពីទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ។ |
| | បណ្តុះបណ្តាលមន្ត្រីពង្រឹងការអនុវត្តច្បាប់ព្រហ្មទណ្ឌទាំងអស់ អំពីសូចនាករនៃការជួញដូរ និងអំពីរបៀបធ្វើការស៊ើបអង្កេតរកមើលបទល្មើសនៃការជួញដូរ និងធានាឲ្យបានថាមានថវិកាគ្រប់គ្រាន់ ដើម្បីរ៉ាប់រងការចំណាយ រួមទាំងថ្លៃដឹកជញ្ជូនផង។ |

| ផ្នែក | សកម្មភាពដែលស្នើឲ្យធ្វើ |
|---|---|
| | បង្កើតនីតិវិធីតុលាការជាលក្ខណៈស្តង់ដា ដើម្បីត្រួតពិនិត្យចារិជ្ជញដូរមនុស្ស ដែលកំពុងរង់ចាំការជំនុំជម្រះក្តី ដើម្បីបង្ការកុំឲ្យឧក្រិដ្ឋជនរត់រួច និងដើម្បីផ្តល់លទ្ធភាពដល់ជនរងគ្រោះឲ្យទទួលបានសំណង។ |
| ការសម្របសម្រួល | ពង្រឹងការសម្របសម្រួលអន្តរក្រសួង ដើម្បីដោះស្រាយពលកម្មកុមារ រួមទាំងប៉ុន្តែមិនកំណត់ត្រឹម ការប្រឹងប្រែងរាយការណ៍ ដែលធ្វើឡើងដោយគណៈកម្មាធិការជាតិស្តីពីការប្រយុទ្ធប្រឆាំងពលកម្មកុមារ ដើម្បីអនុវត្តផែនការសកម្មភាពថ្នាក់ជាតិស្តីពីការប្រយុទ្ធប្រឆាំងទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ។ |
| | បោះពុម្ពផ្សាយជាប្រចាំឆ្នាំ នូវសកម្មភាពដែលបានធ្វើដោយគណៈកម្មាធិការជាតិស្តីពីការប្រយុទ្ធប្រឆាំងពលកម្មកុមារ។ |
| គោលនយោបាយរដ្ឋាភិបាល | បោះពុម្ពផ្សាយជាប្រចាំឆ្នាំ នូវសកម្មភាពដែលបានធ្វើ ក្នុងការអនុវត្តផែនការសកម្មភាព ដើម្បីបង្ការ និងឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ (២០១៧-២០២៣)។ |
| កម្មវិធីសង្គម | បង្កើនបទប្បញ្ញត្តិផ្នែកមីក្រូហិរញ្ញវត្ថុ និងស្ថាប័នផ្តល់ប្រាក់កម្ចី ដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់អ្នកខ្ចី ក្នុងការរងការបង្ខំចិត្តឲ្យធ្វើការដោះបំណុល ផ្តល់ការគាំពារដល់កុមារ ដែលគ្រួសាររបស់ពួកគាត់ ជាជនរងគ្រោះនៃស្ថាប័នមីក្រូហិរញ្ញវត្ថុបែបជញ្ជក់ឈាម។ |
| | បោះពុម្ពផ្សាយលទ្ធផលនៃការស្ទង់មតិអំពីពលកម្មកុមារថ្នាក់ជាតិឆ្នាំ ២០១៩។ |
| | បង្កើនលទ្ធភាពទទួលបានការអប់រំជាមូលដ្ឋានដោយឥតគិតថ្លៃ ដោយលុបបំបាត់ចោលការយកថ្លៃសិក្សាក្រៅផ្លូវការ ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការដឹកជញ្ជូនដែលមានកម្រិត និងហេដ្ឋារចនាសម្ព័ន្ធសាលារៀនដែលមិនគ្រប់គ្រាន់ រួមទាំង “សាលាបណ្តែតទឹក” ដែលគ្មានសុវត្ថិភាព ដែលនៅលើ ឬក្បែរសហគមន៍នេសាទ លុបបំបាត់រនាំងដែលរារាំងការបានចូលរៀននៅសាលារៀន សម្រាប់កុមារជនជាតិភាគតិច កុមារជនជាតិដើមភាគតិច កុមារពិការ ក្មេងស្រី និងកុមារពីជនបទ និងសហគមន៍ដែលគេមើលរម្លង និងផ្តល់សាលារៀនដែលមានសុវត្ថិភាព និងអនាម័យ ដោយមានលទ្ធភាពប្រើប្រាស់ទឹក និងបង្គន់អនាម័យ។ |
| | ផ្តល់ធនធានគ្រប់គ្រាន់ ដល់គ្រប់កម្មវិធីសង្គម ដើម្បីឱ្យពួកគេអាចដោះស្រាយបាន ពេញលេញ នូវបញ្ហាដ៏ធំទូលាយនៃពលកម្មកុមារនៅកម្ពុជា រួមទាំងការកេងប្រវ័ញ្ច ផ្លូវភេទកុមារ តាមអ៊ីនធើណិត។ |